**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ធនាគារជាតិ នៃ កម្ពុជា

លេខ.....ធ៣-០១៩-៣១៤ ធា.ស.ក

ថ្ងៃ សុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៩

## សេចក្តីជូនដំណឹង
## ស្តីពីយុទ្ធនាការស្រឡាញ់ប្រាក់រៀល

ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ដើម្បីអបអរសាទរពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីខ្មែរ ធនាគារជាតិនៃកម្ពុជានឹងរៀបចំយុទ្ធនាការស្រឡាញ់ប្រាក់រៀល ចាប់ពីថ្ងៃចន្ទ ៣រោច ដល់ថ្ងៃព្រហស្បតិ៍ ១៤រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩។

យុទ្ធនាការនេះ នឹងផ្តល់ឱកាសជូនសាធារណជនដែលមានក្រដាសប្រាក់រៀលចាស់ ទក់ ឬរហែក អញ្ជើញមកដូរយកក្រដាសប្រាក់រៀលថ្មី នៅតាមបញ្ជរបេឡារបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត (លើកលែងស្នាក់ការកណ្តាល) រៀងរាល់ម៉ោងធ្វើការ។

ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌនេះ ធនាគារជាតិនៃកម្ពុជា សូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រីទាំងអស់ សូមជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

ទំនាក់ទំនងព័ត៌មានបន្ថែម៖
ទូរស័ព្ទ៖ ០២៣-៩៩០-១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh